ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និងនិយោជកទាំងអស់ឱ្យបានជ្រាបថា ក្នុងឆ្នាំ២០១៨ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តពង្រឹងយន្តការ នីតិវិធី និងការលើកកម្ពស់ការយល់ដឹងអំពីលក្ខណវិនិច្ឆ័យទាំង៧ នៃការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរនិងផលិតស្បែកជើងនៅកម្ពុជា ស្របតាមគោលការណ៍ដែលជាជំនួយបច្ចេកទេសរបស់អង្គការអន្តរជាតិខាងការងារ (ILO)។

ទន្ទឹមនឹងនេះ គណៈកម្មការប្រឹក្សាការងារក៏បានបន្តបង្កើតឱ្យមានក្រុមការងារបច្ចេកទេសត្រីភាគីដែលមានតំណាងភាគីនិយោជកចំនួន ១៦រូប តំណាងភាគីកម្មករនិយោជិតចំនួន ១៦រូប និងតំណាងភាគីរាជរដ្ឋាភិបាលចំនួន ១៦រូប ដើម្បីពិភាក្សាលម្អិតអំពីបម្រែបម្រួលលក្ខណវិនិច្ឆ័យទាំង៧ ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៩។ បន្ទាប់ពីកិច្ចប្រជុំចំនួន ៤ថ្ងៃ ដែលស្មើនឹង ៩លើក ចាប់ពីថ្ងៃទី១០ ខែកញ្ញា ដល់ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ ក្រុមការងារបច្ចេកទេសត្រីភាគី បានបង្រួមគម្លាតនៃតួលេខរៀងខ្លួន និងបានលើកយកតួលេខ ១៨២ដុល្លារអាមេរិក ដែលជាសំឡេងភាគច្រើនរបស់តំណាងភាគីកម្មករនិយោជិត និងតួលេខ ១៧៧ដុល្លារអាមេរិក ដែលជាសំឡេងឯកច្ឆន្ទរបស់តំណាងភាគីនិយោជក និងតំណាងភាគីរាជរដ្ឋាភិបាល ដើម្បីដាក់ជូនគណៈកម្មការប្រឹក្សាការងារប្រជុំពិភាក្សាបន្ត។

នៅរសៀលថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ គណៈកម្មការប្រឹក្សាការងារបានបើកកិច្ចប្រជុំអាណត្តិទី៨ លើកទី១៩ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបន្តពិនិត្យនិងពិភាក្សាលើលទ្ធផលរបស់ក្រុមការងារបច្ចេកទេសត្រីភាគី និងធ្វើការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៩។

ដោយមិនមានតួលេខណាមួយទទួលបានការគាំទ្រជាឯកច្ឆន្ទ គណៈកម្មការប្រឹក្សាការងារបានសម្រេចធ្វើការបោះឆ្នោតជាសម្ងាត់លើតួលេខខាងលើ ដោយគោរពទៅតាមគោលការណ៍និងយន្តការណ៍ដែលបានឯកភាពគ្នាដោយត្រីភាគី និងទទួលបានលទ្ធផលដូចខាងក្រោម៖

- តួលេខចំនួន ១៧៧ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ២៦សំឡេង លើ ២៨សំឡេង
- តួលេខចំនួន ១៨២ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ០សំឡេង លើ ២៨សំឡេង និង
- សំឡេងអនុបវាទចំនួន ២សំឡេង លើ ២៨សំឡេង។

ដូច្នេះ គណៈកម្មការប្រឹក្សាការងារបានស្នើតួលេខចំនួន ១៧៧ (មួយរយចិតសិបប្រាំពីរ) ដុល្លារអាមេរិក ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការពិនិត្យ និងសម្រេចលើប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៩។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៩

យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែយកចិត្តទុកដាក់អំពីសុខុមាលភាព និងជីវភាពរស់នៅសមរម្យរបស់កម្មករនិយោជិត និងផលិតភាពរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន បានសម្រេចបន្ថែមទឹកប្រាក់ចំនួន ៥(ប្រាំ) ដុល្លារអាមេរិក លើទឹកប្រាក់ចំនួន ១៧៧ (មួយរយចិតសិបប្រាំពីរ) ដុល្លារអាមេរិក។ ដូច្នេះ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៩ មានចំនួន ១៨២ (មួយរយប៉ែតសិបពីរ) ដុល្លារអាមេរិកក្នុងមួយខែ ដោយអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

ទន្ទឹមនឹងនេះ ប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ដែលកម្មករនិយោជិតធ្លាប់ទទួលបានកន្លងមក ត្រូវបានរក្សាទុកនៅដដែល មានដូចជា ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ៧ដុល្លារអាមេរិកក្នុងមួយខែ ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ដុល្លារអាមេរិកក្នុងមួយខែ ប្រាក់ថ្លៃបាយសម្រាប់ការធ្វើការងារបន្ថែមម៉ោងដោយស្ម័គ្រចិត្តចំនួន ២ ០០០រៀលក្នុងមួយថ្ងៃ ឬការទទួលបានបាយមួយពេលដោយឥតគិតថ្លៃ និងប្រាក់រង្វាន់អតីតភាពការងារចំនួនពី ២ដុល្លារអាមេរិក ដល់ ១១ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតដែលបានធ្វើការចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី១១។ ដូចនេះជាមធ្យមកម្មករនិយោជិតម្នាក់ នឹងទទួលបានប្រាក់បៀវត្សយ៉ាងតិចចំនួនពី ១៩៩ដុល្លារអាមេរិក ដល់ ២១០ដុល្លារអាមេរិកក្នុងមួយខែ។

ជាមួយគ្នានេះ ដើម្បីជួយសម្រួលបន្ទុកចំណាយអគ្គិសនីរបស់និយោជក រាជរដ្ឋាភិបាលនឹងអនុវត្តអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីថ្មី ០,១៤៧ដុល្លារអាមេរិក ក្នុង ១គីឡូវ៉ាត់ម៉ោង សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចផ្តល់ប្រាក់បន្ថែមចំនួន ៥(ប្រាំ) ដុល្លារអាមេរិក លើការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៩ នេះ ដែលនឹងរួមចំណែកធ្វើឱ្យស្ថានភាពជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង កាន់តែមានភាពល្អប្រសើរឡើងជាងមុន ហើយក៏ជាកត្តាដ៏សំខាន់ក្នុងការជំរុញផលិតភាពផងដែរ។

ក្រសួងក៏សូមថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវ និងមានភាពចាស់ទុំ ក្នុងការពិភាក្សាប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៩ នេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និងនិយោជក មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃសុក្រ ១១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨